មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# របាយការណ៍ប្រចាំឆ្នាំ២០១៤ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

| | |
|---|---|
| ឈ្មោះស្ថាប័ន | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| គោលដៅ | ទស្សនៈវិស័យរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាគឺកម្ពុជាគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសិទ្ធិស្មើគ្នា និងត្រូវបាន ផ្តល់អំណាច ដើម្បីចូលរួមក្នុងលិទ្ធិប្រជាធិបតេយ្យនិងទទួលបាន ការចែក រំលែកផលប្រយោជន៍ពីការអភិវឌ្ឍប្រទេសកម្ពុជា។ |
| រយៈពេល | ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៤ |

## ១. សេចក្តីផ្តើម

នៅក្នុងឆ្នាំ២០១៤ ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាមានសភាពគួរឲ្យព្រួយបារម្ភ។ ច្បាប់ថ្មីៗមួយចំនួន ដែលបានដាក់ចេញដូចជាសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណែត សេចក្តីព្រាងច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល មានលក្ខណៈកាន់តែរឹតត្បិតដល់សេរីភាពបញ្ចេញមតិ ព្រមទាំងការអនុម័តឲ្យប្រើប្រាស់ច្បាប់បីទាក់ទងប្រព័ន្ធតុលាការដែលបានផ្តល់អំណាចគ្រប់គ្រងបន្ថែមទៅលើតុលាការដែលនាំឲ្យមានការជ្រៀតជ្រែកឯករាជ្យភាពដល់ប្រព័ន្ធយុត្តិធម៌។ តុលាការនៅតែត្រូវបានគេប្រើប្រាស់ដើម្បីគំរាមគំហែងទៅដល់អ្នកដែលរិះគន់រដ្ឋាភិបាល និងគណបក្សជំទាស់និងសកម្មជនសិទ្ធិមនុស្ស។

ទោះបីជា ការជាប់គាំងនយោបាយដែលកើតឡើងបន្ទាប់ពីមានជម្លោះក្នុងការបោះឆ្នោតថ្នាក់ជាតិ ឆ្នាំ២០១៣ ត្រូវបញ្ចប់នៅបន្ទាប់ពេលដែលគណបក្សប្រជាជនកម្ពុជានិងគណបក្សសង្គ្រោះជាតិកម្ពុជា (គ.ស.ជ) បានព្រមព្រៀងគ្នាទៅលើការចរចានៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ក៏ដោយ ក៏ស្ថានភាពសិទ្ធិមនុស្សនៅតែបន្តធ្លាក់ចុះ។ គណបក្សទាំង ២ សុទ្ធតែបានអះអាងថាខ្លួនបានឈ្នះក្នុងការបោះឆ្នោត ឆ្នាំ២០១៣ ហើយពេលវេលានៃការចាប់ខ្លួនសមាជិកគ.ស.ជ នាពេលថ្មីៗ ក្នុងអំឡុងការចរចាស្តីពីការកំណែទម្រង់គណៈកម្មាធិការជាតិបោះឆ្នោត អាចបង្ហាញថាការចាប់ខ្លួននោះអាចពាក់ព័ន្ធនឹងហេតុផលនយោបាយ។ រដ្ឋាភិបាលខកខានក្នុងការស៊ើបអង្កេតលើការបង្ក្រាបដ៏សាហាវមកលើក្រុមបាតុកររបស់កងកម្លាំងប្រដាប់អាវុធរបស់រដ្ឋកាលពីខែមករា ឆ្នាំ២០១៤ ដែលបណ្តាលឲ្យមានមនុស្សយ៉ាងតិច៦ នាក់ ត្រូវស្លាប់ និងមនុស្សជាច្រើននាក់ទៀតរងរបួស។ បន្ថែមពីលើនោះ ក្នុងរយៈពេល ពីរបីខែចុងក្រោយក្នុងឆ្នាំ២០១៤ បាតុកម្មដោយសន្តិវិធីតែងតែប្រែទៅជាអំពើហិង្សាដោយសារតែការប្រើប្រាស់កម្លាំងបង្ក្រាបហួសហេតុរបស់កងកម្លាំងសន្តិសុខដើម្បីបំបែកក្រុមបាតុករ។ ឧទាហរណ៍ នៅថ្ងៃទី១៦ - ១៧ ខែកក្កដា ឆ្នាំ២០១៤ សមាជិកជាន់ខ្ពស់ចំនួន ៦ នាក់ របស់ គ.ស.ជ ត្រូវបាន

ចាប់ខ្លួន និងចោទប្រកាន់ពីបទ "កុប្បកម្ម" បន្ទាប់ពីអំពើហិង្សាដែលបានកើតឡើង ក្នុងអំឡុងបាតុកម្មរបស់ គ.ស.ជ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ក្នុងតំបន់ជុំវិញទីលានប្រជាធិបតេយ្យនៅភ្នំពេញ។[1]

ក្នុងរយៈពេលមួយឆ្នាំ ២០១៤ សកម្មជនដីធ្លី អ្នកធ្វើការផ្នែកប្រព័ន្ធផ្សព្វផ្សាយ អ្នកដឹកនាំសហជីព និងបុគ្គលិកផ្នែកសិទ្ធិមនុស្សនៅទូទាំងប្រទេសក្លាយជាគោលដៅនៃការគំរាមកំហែងផ្នែកផ្លូវច្បាប់ ការចាប់ខ្លួនដោយអំពើចិត្ត និងការគំរាមសម្លាប់។ ឧទាហរណ៍ គ្រាន់តែរយៈពេល៣៦ ម៉ោងនៃការចាប់ខ្លួនសកម្មជនបឹងកក់ ៧ នាក់ កាលពីថ្ងៃទី១០ ខែវិច្ឆិកា អ្នកទាំងអស់នោះត្រូវបានសាកសួរ ហើយឃុំខ្លួនដោយព្រះរាជអាជ្ញា និងចោទប្រកាន់ពីបទបង្កការកកស្ទះចរាចរណ៍ បន្ទាប់មកត្រូវបើកសវនាការ សម្រេចទោស និងផ្តន្ទាទោស ក្នុងសវនាការដ៏អយុត្តិធម៌ឲ្យជាប់ពន្ធនាគាររយៈពេល ១ ឆ្នាំ និងពិន័យចំនួន ៥០០ ដុល្លារ ដែលជាចំនួនទឹកប្រាក់អតិបរមាដែលបានកំណត់ក្នុងច្បាប់។[2] បន្ថែមពីលើនោះ ស្ត្រីចំនួន ៣ នាក់ និងព្រះសង្ឃមួយអង្គ ក៏ត្រូវប្រឈមនឹងវាសនាស្រដៀងគ្នានេះនៅថ្ងៃបន្ទាប់គឺត្រូវឃុំខ្លួន ខណៈពេលដែលធ្វើការតវ៉ាប្រឆាំងនឹងការចាប់ខ្លួនសកម្មជន និងត្រូវបានកាត់ទោសយ៉ាងឆាប់រហ័សពីបទប្រឆាំងនឹងមន្ត្រីរដ្ឋាភិបាល។ សាលាឧទ្ធរណ៍បានតម្កល់សេចក្តីសម្រេចទោសរបស់អ្នកទាំងនោះកាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥។

ប៉ុន្តែ នៅពីក្រោយស្ថានភាពដ៏ដុនដាបនេះ ក៏មានការវិវឌ្ឍន៍ដែលគួរឲ្យកត់សម្គាល់មួយចំនួនផងដែរ។ តំណាងរាស្ត្រតាមរយៈ គណៈកម្មការជំនាញរបស់ខ្លួន បានបើកឲ្យមានការចូលរួមក្នុងកិច្ចពិគ្រោះយោបល់ស្តីពីបញ្ហាសិទ្ធិមនុស្ស សិទ្ធិដីធ្លី[3] សិទ្ធិទទួលបានព័ត៌មាន និងបញ្ហាស្ត្រី ជាដើម ជាមួយអង្គការសង្គមស៊ីវិល។ នេះបានផ្តល់ឱកាសសម្រាប់អង្គការសង្គមស៊ីវិលដើម្បីលើកយកនូវអនុសាសន៍ស្តីពីបញ្ហាទាំងនេះមកបង្ហាញនៅក្នុងថ្នាក់ជាតិ។

## ២. ទស្សនភាព

ក្នុងអំឡុងរយៈពេលនៃរបាយការណ៍ ម.ស.ម.ក បានចេញផ្សាយសេចក្តីថ្លែងការណ៍/វិចារណកថាព័ត៌មាន/លិខិតចំហ ចំនួន **៤៦** សេចក្តីថ្លែងការណ៍រួម ចំនួន **១៨** សេចក្តីប្រកាសព័ត៌មានបន្ទាន់ គម្រោងអ្នកការពារសិទ្ធិមនុស្ស/ ឬ គម្រោងសេរីភាពបញ្ចេញមតិ ចំនួន **៩** កំណត់ត្រាសង្ខេប ចំនួន **១៦** របាយការណ៍បែបស្រាវជ្រាវ ចំនួន **៣** សលាកប័ត្រព័ត៌មាន ចំនួន **៦** វិភាគផ្នែកច្បាប់ ចំនួន **១** និងឯកសារផ្សេងៗទៀត (រាប់បញ្ចូលទាំងរបាយការណ៍ស្រមោលទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ផ្តោតលើស្ថានភាពសេរីភាពបញ្ចេញមតិនៅក្នុងប្រទេស និងស្នើអនុសាសន៍ជូនទៅរដ្ឋាភិបាល លិខិតអន្តរាគមន៍ទៅកាន់ក្រុមហ៊ុនដែលជាប់ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សក្នុងឧស្សាហកម្មរោងចក្រ ឬក្នុងបរិបទនៃជម្លោះដីធ្លីចំនួន ៧ របាយការណ៍ជាសង្ខេបចំនួន១ ខិត្តបណ្ណចំនួន ២ និងរបាយការណ៍លទ្ធផលនៃសិក្ខាសាលា/គោលនយោបាយ

[1] សេចក្តីថ្លែងការណ៍របស់ ម.ស.ម.ក "ម.ស.ម.ក អំពាវនាវឲ្យមានការដោះលែងភ្លាមៗ និងគ្មានលក្ខខណ្ឌនៃថ្នាក់ដឹកនាំគណបក្សប្រឆាំង និងអំពាវនាវឲ្យមានការបញ្ចប់អំពើហិង្សា" (ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤) http://bit.ly/1yDeFFr

[2] សេចក្តីប្រកាសព័ត៌មានបន្ទាន់ ម.ស.ម.ក "សមាជិកនៃសហគមន៍បឹងកក់ត្រូវបានចាប់ខ្លួន ឃុំខ្លួន និងកាត់ទោសក្នុងរយៈពេល ៣៦ ម៉ោង" (ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៤) http://bit.ly/1wn9vG5

[3] https://www.facebook.com/cchrcambodia/photos/pb.206984670430.-2207520000.1422270215./ 10154740992190431/?type=3&theater

សង្ខេបចំនួន ២។ ឯកសារទាំងនេះស្តីពីបញ្ហាសិទ្ធិមនុស្សជាច្រើនចម្រុះគ្នា ដែលមានដូចជា សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស (ដែលផ្តោតលើឧស្សាហកម្មរោងចក្រ) សិទ្ធិស្ត្រី(ដែលផ្តោតលើតំណាងស្ត្រីក្នុងវិស័យនយោបាយ) កំណែទម្រង់នយោបាយ/ប្រព័ន្ធបោះឆ្នោត/អភិបាលកិច្ច សេរីភាពបញ្ចេញមតិ និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ កំណែទម្រង់តុលាការ អ្នកការពារសិទ្ធិមនុស្ស សិទ្ធិជនជាតិដើមភាគតិ និងច្រើនទៀត។ បន្ថែមពីលើនោះ ម.ស.ម.ក បានរៀបចំកម្មវិធីវិទ្យុផ្សាយផ្ទាល់ចំនួន**១៦៧** ដែលក្នុងកិច្ចពិភាក្សានីមួយៗផ្តោតលើប្រធានបទខាងលើមួយឬច្រើន រួមទាំងមានប្រធានបទពាក់ព័ន្ធនឹងសិទ្ធិដីធ្លីចំនួន៨ ធុរកិច្ចនិងសិទ្ធិមនុស្សចំនួន១០ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ចំនួន១១ និងអ្នកការពារសិទ្ធិមនុស្សចំនួន **២៧**។ ម.ស.ម.ក រៀបចំសិក្ខាសាលាទាក់ទងនឹងសេរីភាពបញ្ចេញមតិចំនួន២ ដង សិក្ខាសាលាស្តីពីយុវជន និងកំណែទម្រង់ប្រព័ន្ធបោះឆ្នោតចំនួន១ និងសិក្ខាសាលាស្តីពីការបង្កើតវចនសព្ទទាក់ទងនឹងអ្នកស្រលាញ់ភេទដូចគ្នានិងសិក្ខាសាលារួមមួយពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្ស។ ម.ស.ម.ក រៀបចំវគ្គបណ្តុះបណ្តាលចំនួន៤៤ នៅលើប្រធានបទផ្សេងៗដូចជាព័ត៌មានបច្ចេកវិទ្យា បណ្តាញសង្គម សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា សិទ្ធិដីធ្លី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ធុរកិច្ច និងសិទ្ធិមនុស្ស និងវិធានការសន្តិសុខសម្រាប់អ្នកការពារសិទ្ធិមនុស្ស។

ចំណុចដែលគួរឲ្យចាប់អារម្មណ៍មួយទៀត ម.ស.ម.ក បានរៀបចំយុទ្ធនាការចំនួន ៣ ដង។ ដើម្បីរំលឹកដល់ទិវាអន្តរជាតិស្តីពីសិទ្ធិទទួលបានការពិតនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ ម.ស.ម.ក បានសម្ពោធ "យុទ្ធនាការឯណាទៅយុត្តិធម៌ខ្ញុំ?" មានគោលបំណងអំពាវនាវឲ្យដៃគូ និងអ្នកគាំទ្រចូលរួមជាមួយ ម.ស.ម.ក ដើម្បីទាមទារស្វែងរកនូវការពិតនិងយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើហិង្សាដោយកងកម្លាំងសន្តិសុខ។ នៅក្នុងខែវិច្ឆិកា ម.ស.ម.ក បានរៀបចំយុទ្ធនាការ មុនទិវាអន្តរជាតិបញ្ឈប់និទណ្ឌភាពនៅថ្ងៃទី២៣ ខែវិច្ឆិកា តាមរយៈការបង្កើតនូវញត្តិរូបថតស្នើសុំឲ្យរដ្ឋាភិបាលបញ្ឈប់និទណ្ឌភាព។ ម.ស.ម.ក ទទួលបានរូបថតប្រហែលជា ២៨០។ ផ្ទាំងបដាដ៏ធំមួយត្រូវបានបង្កើតឡើងដោយរូបថត ដែលត្រូវបានផ្ញើទៅកាន់ក្រសួងយុត្តិធម៌ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៤។ បន្ថែមពីលើនោះ ម.ស.ម.ក ក៏បានរៀបចំការតាំងពិព័រណរូបថតក្រោមប្រធានបទ "ឯណាទៅយុត្តិធម៌ខ្ញុំ?"នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៤ មុនទិវាសិទ្ធិមនុស្សអន្តរជាតិមួយថ្ងៃ។ គោលបំណងនៃការតាំងពិព័រណរូបថតនេះគឺដើម្បីលើកកម្ពស់ការយល់ដឹង ដល់សាធារណជនផ្សេងៗឲ្យបានទូលំទូលាយ ស្តីពីបញ្ហានិទណ្ឌភាពនៅប្រទេសកម្ពុជា និងដើម្បីចែករំលែករឿងរ៉ាវនៃជនរងគ្រោះចំនួន ១២ នាក់ ដោយសារតែវប្បធម៌និទណ្ឌភាព រួមមាន អ្នកសារព័ត៌មាន ជនរងគ្រោះនៃជម្លោះដីធ្លី បាតុករ សមាជិកសហជីពការងារ និងក្រុមអ្នកស្រលាញ់ភេទដូចគ្នា និងអ្នកដទៃផ្សេងទៀត។ ការតាំងពិព័រណរូបថតនេះបានបើកឲ្យចូលទស្សនារហូតដល់ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤។

### ៣. សកម្មភាពដែលដំណើរការបានល្អ និងមិនល្អ

សេចក្តីប្រកាសព័ត៌មានបន្ទាន់ ម.ស.ម.ក ចេញផ្សាយនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការចោទប្រកាន់ និងការឃុំខ្លួន ថ្នាក់ដឹកនាំ និងសមាជិកសហជីព បានទាញការចាប់អារម្មណ៍ពី គម្រោងសង្កេតការណ៍ដើម្បីការការពារអ្នកការពារសិទ្ធិមនុស្សរបស់អង្គការពិភពលោកប្រយុទ្ធប្រឆាំងនឹងទារុណកម្ម និងសហ

ព័ន្ធអន្តរជាតិស្តីពីសិទ្ធិមនុស្ស ។ ជាលទ្ធផល អង្គការអន្តរជាតិចំនួន ២ នេះបានចេញនូវ សេចក្តីអំពាវនាវបន្ទាន់រួមគ្នា ស្នើសុំឲ្យអាជ្ញាធរកម្ពុជាធានានូវបូរណភាពរូបរាងកាយ និងផ្លូវចិត្តរបស់អ្នកដែលត្រូវបានចាប់ខ្លួនទាំងនោះ ក្នុងគ្រប់កាលៈទេសៈទាំងអស់ដើម្បីបញ្ចប់នូវសកម្មភាពយាយីរួមទាំង ការយាយីផ្នែកច្បាប់ ដើម្បីអនុលោមទៅតាមសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងដើម្បីធានាការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាននៅកម្ពុជា។ សេចក្តីប្រកាសព័ត៌មានបន្ទាន់មួយទៀតដែលបានចេញផ្សាយ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤ ស្តីពីការគំរាមកំហែងបិទអង្គការក្នុងស្រុកមួយឈ្មោះថា ពន្លកខ្មែរ។

មានករណីអ្នកការពារសិទ្ធិមនុស្សច្រើនជាង ៣៥ ករណី ទទួលបានការគាំទ្រពីគម្រោង និងឃើញថាការគំរាមកំហែង និងភាពប្រថុយប្រថានមានការថយចុះ បន្ទាប់ពីគម្រោងបានផ្តល់នូវជំនួយដល់ពួកគេ។ បន្ថែមពីលើនោះ ការគាំទ្ររបស់ ម.ស.ម.ក ក្នុងករណីគំរាមកំហែង ឬក៏រំលោភសិទ្ធិមនុស្សបានបង្កើននូវទំនុកចិត្តរបស់គម្រោងអ្នកការពារសិទ្ធិមនុស្សក្នុងការអនុវត្តសកម្មភាពសិទ្ធិមនុស្ស។

ក្នុងគម្រោងសង្កេតការណ៍សវនាការ ម.ស.ម.ក ទទួលបានមូលនិធិខ្នាតតូចមកពី ការប្រកួតប្រជែងយុត្តិធម៌ពិភពលោក ដើម្បីផលិតវីដេអូខ្លីៗស្តីពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នៅកម្ពុជា។ នេះជាឱកាសដ៏ល្អសម្រាប់គម្រោងសង្កេតការណ៍សវនាការដើម្បីផ្សព្វផ្សាយទៅដល់មនុស្សភាគច្រើន។ ជ័យលាភីនេះត្រូវបានប្រកាសនៅលើគេហទំព័រ ការប្រកួតប្រជែកយុត្តិធម៌ពិភពលោក កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤។ បន្ទាប់ពីការប្រកាសជ័យលាភី សារព័ត៌មានភ្នំពេញប៉ុស្តិ៍ បានរាយការណ៍ពីជ័យលាភីនេះនៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤។

បន្ថែមពីលើនេះ ក៏មានអង្គការអន្តរជាតិមួយចំនួនដែលធ្វើការលើការសង្កេតការណ៍សវនាការ និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលបានទាក់ទងមកគម្រោងសង្កេតការណ៍សវនាការ ដើម្បីស្វែងរកកិច្ចសហការណ៍ក្នុងវិស័យនេះដែលមានដូចជា សវនាការបើកចំហ និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌អន្តរជាតិ។

ដោយសារតែបញ្ហាចលាចលកើតឡើងដែលបណ្តាលមកពីមហាបាតុកម្មរបស់កម្មកររោងចក្រកាត់ដេរ និងកម្មករក្នុងវិស័យផ្សេងទៀតនិងរបស់គណបក្សប្រឆាំងកាលពីដើមឆ្នាំនេះ ទើបសកម្មភាពការងារមួយចំនួនរបស់មជ្ឈមណ្ឌលដូចជាវគ្គបណ្តុះបណ្តាលដែលរៀបចំដោយគម្រោងធុរកិច្ចនិងសិទ្ធិមនុស្សមានការយឺតយ៉ាវ។ ដោយសារតែដៃគូសំខាន់ៗត្រូវរវល់ជាមួយនឹងការឆ្លើយតបទៅនឹងវិបត្តិនយោបាយ និងដោយសារតែលទ្ធផលនៃការបង្ក្រាបមកលើសេរីភាពបញ្ចេញមតិ និងសេរីភាពនៃការជួបប្រជុំ ធ្វើឲ្យមានការពិបាកក្នុងការកៀងគរអ្នកចូលរួមសម្រាប់កម្មវិធីនីមួយៗ។

**៤. មេរៀន**

ក្នុងករណីមួយចំនួន ម.ស.ម.ក មិនមានឱកាសផ្តល់ជំនួយផ្នែកច្បាប់ទៅកាន់អ្នកការពារសិទ្ធិមនុស្ស ឬសូម្បីតែពេលដែលជំនួយបែបនោះត្រូវបានធានារួចទៅហើយ ដោយសារតែករណីទាំងនេះត្រូវទម្លាក់ការចោទ

ប្រកាន់បន្ទាប់ពីមន្ត្រីនគរបាលបង្គាប់ឲ្យចុះហត្ថលេខាលើកិច្ចសន្យាថានឹងមិនពាក់ព័ន្ធនឹងសកម្មភាពធ្វើបាតុកម្ម ឬសកម្មភាពខុសច្បាប់ណានាពេលខាងមុខនោះទេ។

ករណីអ្នកការពារសិទ្ធិមនុស្សដែលល្បីឈ្មោះមួយចំនួន ដែលទទួលបានការចាប់អារម្មណ៍ពីសហគមន៍អន្តរជាតិគួរតែបង្ហាញអោយបានច្បាស់ពីការគំរាមកំហែងដែលប្រើនៅថ្នាក់សហគមន៍មូលដ្ឋាន ដែលនៅទីនោះមិនអាចទទួលបានការចាប់អារម្មណ៍ពីអន្តរជាតិនោះទេ។ គម្រោងបានសិក្សាពីសារៈសំខាន់នៃការលើកយកករណីរបស់អ្នកការពារសិទ្ធិមនុស្សទាំងអស់ដែលជាគោលដៅនៃការគំរាមកំហែង។ សេចក្តីប្រកាសព័ត៌មានបន្ទាន់ត្រូវបានផ្សព្វផ្សាយទៅ អង្គការជាតិ និងអន្តរជាតិ ម្ចាស់ជំនួយ ស្ថានទូត ក្រុមសេរីភាពបញ្ចេញមតិ អ្នកការពារសិទ្ធិមនុស្សដទៃទៀត និងការិយាល័យអង្គការសហប្រជាជាតិនៅកម្ពុជា ដើម្បីលើកកម្ពស់ការយល់ដឹងពីការរំលោភបំពាន និងដើម្បីដាក់សម្ពាធទៅលើអាជ្ញាធរកម្ពុជាដើម្បីបញ្ឈប់ការរំលោភបំពានទាំងនេះ។

**៥. គោលការណ៍ផ្អែកលើយេនឌ័រ និងសិទ្ធិជាមូលដ្ឋាន**

ម.ស.ម.ក បានខិតខំប្រឹងប្រែងជានាឲ្យមានសមភាពយេនឌ័រក្នុងស្ថាប័ន ដែលមានបញ្ចូលក្នុងកម្មវិធី និងគម្រោងទាំងអស់របស់ខ្លួន។ ក្នុងអំឡុងការអនុវត្តគម្រោង ម.ស.ម.ក បានខិតខំជំនះឲ្យមានការចូលរួមពីស្ត្រីដូចជា ការរៀបចំកម្មវិធីសម្រាប់ស្ត្រីសុទ្ធ ក៏ជានាឲ្យមានតំណាងបុរស និងស្ត្រីជាវាគ្មិនក្នុងព្រឹត្តិការណ៍ផ្សេងៗ (បង្ហាញនូវគំរូល្អៗសម្រាប់បុគ្គលទាំង ២ ភេទ) និងក្នុងគ្រប់ឱកាសផ្សេងៗបានលើកឡើងពីស្ថានភាពស្មើគ្នាស្របតាមច្បាប់រវាងបុរសនិងស្ត្រី លើបញ្ហាសិទ្ធិមនុស្ស។ មិនតែប៉ុណ្ណោះ ក្នុងព្រឹត្តិការណ៍ខ្លះទៀតដែលរៀបចំដោយ ម.ស.ម.ក ចំនួនអ្នកចូលរួមដែលជាបុរសតិចជាងចំនួនអ្នកចូលរួមដែលជាស្ត្រី។ ឧទាហរណ៍ក្នុងកម្មវិធី "កិច្ចសន្ទនាស្ត្រី" រៀបចំដោយ ម.ស.ម.ក ដែលមានអ្នកចូលរួមជាស្ត្រីចំនួន ៦៩,៧៤% នៃអ្នកចូលរួមសរុប (៣៨០នាក់)។ ទោះបីជាគម្រោង ជំរុញឲ្យមានការចូលរួមពីបុរស និងស្ត្រី ប៉ុន្តែប្រជាពលរដ្ឋកម្ពុជាភាគច្រើននៅតែចាត់ទុកថាការពិភាក្សាបញ្ហាពាក់ព័ន្ធស្ត្រីគឺសម្រាប់តែស្ត្រី ជាលទ្ធផលធ្វើឲ្យបុរសភាគច្រើនស្ទាក់ស្ទើរក្នុងការចូលរួម។ ម.ស.ម.ក តែងតែជំរុញឲ្យបុរសចូលរួមក្នុងព្រឹត្តិការណ៍ទាំងនេះ ដោយសារតែ ម.ស.ម.ក ជឿជាក់ថាការគាំទ្រពីបុរសនឹងជួយលើកកម្ពស់ឲ្យស្ត្រីកាន់តែចូលរួមបានច្រើនក្នុងវិស័យនយោបាយ៕

---ចប់---